**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះវិហារ**

សំណុំរឿងព្រហ្មទណ្ឌលេខ ៣៩៩
ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០
សំណុំរឿងជំនុំជម្រះលេខ ២៧១
ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១
សាលក្រមព្រហ្មទណ្ឌ
លេខ ៤៧ (ច)
ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១

**គោរពនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តព្រះវិហារ**

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោងប្រាំបួន និងម្ភៃនាទីព្រឹក ដោយមានសមាសភាព៖

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ
លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះវិហារ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះវិហារ

ដើម្បីធ្វើការជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៩៩ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] ហួត ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ [redacted] ខេត្តព្រះវិហារ មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted] ហៃល (ស្លាប់) ម្តាយឈ្មោះ [redacted] ផន (ស្លាប់) ប្រពន្ធឈ្មោះ [redacted] សាភិត (រស់) មានកូនចំនួន ០៤នាក់ ទោសពីមុន គ្មាន។ (ក្រៅឃុំ)

២.ឈ្មោះ [redacted] ផល ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ [redacted] ខេត្តសៀមរាប មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted] ហៃម (ស្លាប់) ម្តាយឈ្មោះ [redacted] ហឿន (ស្លាប់) ប្រពន្ធឈ្មោះ [redacted] លេងមាន (រស់) មានកូនចំនួន ០៣នាក់ ទោសពីមុន គ្មាន។ (ក្រៅឃុំ)

៣.ឈ្មោះ [redacted] មួន ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ [redacted] ខេត្តព្រះវិហារ មានទីលំ



Scanned with CamScanner

នៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted] មិន (រស់) ម្តាយឈ្មោះ [redacted]ចេង (រស់) ប្រពន្ធឈ្មោះ [redacted]យ៉ា (រស់) មានកូនចំនួន ០៦នាក់ ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ត្រូវជាប់ចោទពីបទ កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅភូមិជាំស្រែ ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីដើមឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦២ ចំណុច១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

ដែលមានលោក[redacted]ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទទាំង ០៣រូប ខាងលើ

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ១១៥៧ ដ.ស.ព ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តព្រះវិហារ

-បានឃើញដីកាដំណោះស្រាយលេខ ២៧៤០ ព្រ/ទ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះវិហារ

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៧៥៥/២០២១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តព្រះវិហារ

-បានឃើញដីកាសម្រេចដាក់រឿងទៅជំនុំជម្រះលេខ ៨២០/២០២១ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តព្រះវិហារ

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅៈ

កាលពីដើមឆ្នាំ២០២០ មានករណី កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីធ្វើជាកម្មសិទ្ធិ ស្ថិតនៅដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព ស្ថិតនៅភូមិជាំស្រែ ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ បង្កឡើងដោយជនល្មើសទាំង ០៣រូប ខាងលើ បានចូលទៅកាប់ព្រៃ ដើម្បីយកដីមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដោយគ្មានលិខិតអនុញ្ញាតប្រាកដមែន។

## នាពេលសវនាការ

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហួត បានឆ្លើយថា ខ្លួនពិតជាកាន់កាប់ដីនេះ តាំងពីដើមឆ្នាំ២០២០ មកម្លេះ ដោយខ្លួនបានកាប់រានព្រៃសហគមន៍នេះ ដោយប្រើកាំបិតផ្គាក់ ដើម្បីអាស្រ័យផលលើដីនេះ។ ប៉ុន្តែបច្ចុប្បន្ន ខ្លួនបានប្រគល់ដីចំនួនប្រហែល ០៣ហិកតា ដោយបានធ្វើកិច្ចសន្យាប្រគល់ដីឲ្យទៅមន្ទីរបរិស្ថានវិញហើយ។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ផល បានឆ្លើយថា ខ្លួនពិតបានចូលទៅកាប់រានដីព្រៃសហគមន៍ដើម្បីយកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនប្រាកដមែន ដោយប្រើកាំបិត។ តែសព្វថ្ងៃនេះ ខ្លួនមិនបានទៅអាស្រ័យផលលើដីសហគមន៍នេះទេ ហើយខ្លួនបានប្រគល់ដីចំនួនប្រហែល ០១ហិកតា ដោយបានធ្វើកិច្ចសន្យាប្រគល់ដីឲ្យទៅមន្ទីរបរិស្ថានវិញហើយ។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] មួន បានឆ្លើយថា ខ្លួនពិតជាបានចូលទៅកាប់គាស់ រុករានដីព្រៃសហគមន៍ ដើម្បីយកមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនប្រាកដមែន ដោយប្រើកាំបិត។ តែសព្វថ្ងៃនេះ ខ្លួនបានប្រគល់ដីចំនួនប្រហែល ០១ហិកតា ដោយបានធ្វើកិច្ចសន្យាប្រគល់ដីឲ្យទៅមន្ទីរបរិស្ថានវិញហើយ។



Scanned with CamScanner

-លោក [redacted] ញឹម អនុប្រធានមន្ទីរបរិស្ថានខេត្តព្រះវិហារ បានឆ្លើយបំភ្លឺនាពេលសវនាការថា កាលពីដើមឆ្នាំ២០២០ មានករណី កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីធ្វើជាកម្មសិទ្ធិ ស្ថិតនៅដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព ស្ថិតនៅភូមិជាំស្រែ ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ បង្កឡើងដោយជនល្មើសឈ្មោះ [redacted] ហួត ភេទប្រុស ឈ្មោះ [redacted] ផល ភេទប្រុស និងឈ្មោះ [redacted] មួន ភេទប្រុស ប្រាកមដែន។ ប៉ុន្តែបច្ចុប្បន្ននេះ ជនល្មើសខាងលើនេះ បានសុខចិត្តប្រគល់ដីដែលពួកគាត់បានកាប់ទន្ទ្រានខាងលើ មកមន្ទីរបរិស្ថានខេត្តព្រះវិហារគ្រប់គ្រងវិញហើយ ដោយមិនការបង្ខិតបង្ខំ។ បច្ចុប្បន្ននេះ មន្ទីរបរិស្ថានបានសម្រេចដកពាក្យបណ្ដឹងវិញហើយ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា ប្ដឹងស្នើសុំរក្សាបទចោទប្រកាន់នៅដដែល និងស្នើសុំតុលាការធ្វើការពិចារណា និងសម្រេចតាមច្បាប់។

-លោក [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទទាំង ០៣រូបខាងលើ បានធ្វើសេចក្ដីសន្និដ្ឋានថា កូនក្ដីខ្លួនទទួលស្គាល់កំហុស និងព្រមសារភាពទោសកំហុសរួច និងព្រមប្រគល់ដីឲ្យទៅមន្ទីរបរិស្ថានខេត្តព្រះវិហារវិញហើយ មន្ទីរបរិស្ថានខេត្តព្រះវិហារយល់ព្រមដកពាក្យបណ្ដឹង ហេតុដូច្នេះ ស្នើសុំតុលាការពិចារណា និងសម្រេចឲ្យរួចផុតបទចោទប្រកាន់។

ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ជនជាប់ចោទទាំង ០៣រូបនាពេលសវនាការ

ក្រោយពីបានស្ដាប់ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌នាពេលសវនាការ

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្ដុតាង និងឯកសារនានាដែលមានក្នុងសំណុំរឿង

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តព្រះវិហារ យល់ឃើញថា

១.តុលាការជំនុំជម្រះទទួលបានបណ្ដឹងតាមដីកាដំណោះស្រាយលេខ **២៧៤០** ព្រ/ទ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះវិហារ ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ហួត ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ឈ្មោះ [redacted] ផល ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) និងឈ្មោះ [redacted] មួន ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) មកតុលាការដើម្បីជំនុំជម្រះ ពីបទ **កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីធ្វើជាកម្មសិទ្ធិ** ប្រព្រឹត្តនៅភូមិជាំស្រែ ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីដើមឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **៦២ ចំណុច១** នៃច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ។

២.តាមចម្លើយសារភាពរបស់ជនជាប់ចោទទាំង ០៣រូបខាងលើ ចម្លើយបំភ្លឺរបស់មន្ត្រីនគរបាលយុត្តិធម៌ និងតាមការពិនិត្យភស្ដុតាងឯកសារនានានៅក្នុងសំណុំរឿង បង្ហាញឲ្យតុលាការឃើញថា ជនជាប់ចោទទាំង០៣រូបខាងលើ ពិតជាបានធ្វើសកម្មភាពកាប់គាស់ រុករានព្រៃ ដោយប្រើប្រាស់កាំបិតផ្គាក់ជាមធ្យោបាយ ដើម្បីយកដីធ្វើជាកម្មសិទ្ធិប្រាកដមែន ដីដែលជនជាប់ចោទបានធ្វើសកម្មភាពកាប់គាស់ រុករានដីព្រៃ ឆ្ការនេះ ពិតជាស្ថិតនៅក្នុងដែនការពាររបស់មន្ទីរបរិស្ថាន កម្ម



Scanned with CamScanner

សិទ្ធិរដ្ឋប្រាកដមែន ហេតុដូច្នេះ តុលាការកំណត់បានថា ជនជាប់ចោទទាំង ០៣រូបខាងលើ ពិតជាមានចេតនា និងបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការពីបទ **កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃដើម្បីជាកម្មសិទ្ធិ** ប្រព្រឹត្តនៅចំណុចភូមិជាំស្រែ ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីដើមឆ្នាំ២០២០ ប្រាកដមែន ទោះបីជាជនជាប់ចោទបានធ្វើកិច្ចសន្យាប្រគល់ដីឲ្យមកមន្ទីរបរិស្ថាន ហើយមន្ទីរបរិស្ថានបានដកពាក្យបណ្ដឹងរួចហើយ គឺបទល្មើសនៅតែមានបណ្ដឹងអាជ្ញាមិនទាន់រលត់ ហេតុដូច្នេះ តុលាការមូលដ្ឋានគ្រប់គ្រាន់សម្រេចតាមច្បាប់បាន តាមបញ្ញត្តិមាត្រា ៦២ ចំណុច១ នៃច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ។

៣.តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋាន ស្នើសុំរក្សាបទចោទប្រកាន់ទុកជាការ និងស្នើសុំឲ្យតុលាការធ្វើការពិចារណា និងសម្រេចតាមច្បាប់ គប្បីតុលាការពិចារណា។

៤.អំពើប្រព្រឹត្តរបស់ជនជាប់ចោទ ធ្វើឲ្យមានការប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គម ដែលត្រូវបានច្បាប់ការពារតាមបញ្ញត្តិមាត្រា ៦២ ចំណុច១ នៃច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ។

៥.ជនជាប់ចោទទាំង ០៣រូប ជានីតិជនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការយល់ដឹងខុសត្រូវពីផលវិបាក ដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន និងមិនមានភស្ដុតាងណាមួយ បញ្ជាក់ពីការមានវិបល្លាស ស្មារតីរបស់ជនជាប់ចោទ ដូច្នេះជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះមុខច្បាប់។

៦.មានពិរុទ្ធភាព និងភស្ដុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ហួត ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ឈ្មោះ [redacted] ផល ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) និងឈ្មោះ [redacted] មួន ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ពីបទ **កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃដើម្បីធ្វើជាកម្មសិទ្ធិ** ប្រព្រឹត្តនៅភូមិជាំស្រែ ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីដើមឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៦២ ចំណុច១ នៃច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ។

៧.ជនជាប់ចោទ ០៣រូប បានសារភាពនូវកំហុសរបស់ខ្លួន និងបានប្រគល់ដីជាកម្មសិទ្ធិរដ្ឋដែលពួកខ្លួនបានកាន់កាប់ដោយខុស ជនជាប់ចោទទើបប្រព្រឹត្តជាដំបូង ហេតុដូច្នេះ តុលាការគប្បីតុលាការផ្ដល់ស្ថានសម្រាលនៃទោស និងពិចារណាអំពីលក្ខខណ្ឌដែលនាំឲ្យមានការព្យួរទោសទៅលើជនជាប់ចោទទាំង ០៣រូប បាន តាមបញ្ញត្តិមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

## <u>ហេតុដូច្នេះ សាលាដំបូងខេត្តព្រះវិហារ</u>

## <u>វិនិច្ឆ័យសេចក្ដី</u>

**ផ្ដន្ទាទោសលើ៖**

ក.ឈ្មោះ [redacted] ហួត ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិខ្មែរ

ខ.ឈ្មោះ [redacted] ផល ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ

គ.ឈ្មោះ [redacted] មួន ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ



Scanned with CamScanner

ដាក់ពន្ធនាគារម្នាក់ៗ កំណត់ ០៥ (ប្រាំ) ឆ្នាំ តែទោសនេះអនុវត្តព្យួរ ពីបទ កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅភូមិជាំស្រែ ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ តាមបញ្ញត្តិមាត្រា ៦២ ចំណុច១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងតាមបញ្ញត្តិមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ កាលពីដើមឆ្នាំ២០២០។

សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ហ្វត ឈ្មោះ [redacted] ផល និងឈ្មោះ [redacted] មួន។

*ទុកសិទ្ធិឲ្យភាគីប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។*

ថ្ងៃព្រហស្បតិ៍ ៤រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

ព្រះវិហារ, ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១

| **ក្រឡាបញ្ជីសវនាការ** | **ក្រុមប្រឹក្សាជំនុំជម្រះ** | **ក្រុមប្រឹក្សាជំនុំជម្រះ** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

**បានឃើញ**
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ៤រោច ខែធ្នូ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
ព្រះវិហារ, ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១
**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner